នាំគ្នាតែទៅ ។

នាងចូលក្នុងប្រាង្គ ប្រាសាទហើយនាង សែនសោយសោកសៅ

សះស្រន់ក្នុងចិត្ត ផ្អែកផ្អឹកក្តួលក្តៅ ទុក្ខម៉ោងម្ដៅ

ម្ដងមិនស្រាកស្រាន្ត ។

ក្នុងចិត្តគិតថា ទម្រៀមស្នេហា គួរគួចុកណា

លាភលះស្មុះមក រកប្អូនកល្យាណ ទំនងនឹកស្មាន

ជាគេករុណា ។

មិនដឹងអកុសល តែងតាមមកដល់ មកផ្តាច់ស្នេហា

បង្អួចបង្អាន ឲ្យបានឃ្លាតឃ្លា ឃ្លាតខ្លួនប្អូនគ្នា

ទៀមអើយឆ្ងាយសល់ ។

៦៥៥– ខប្រុសពន្លក ប្រៀបដូចពពក ពពានដោយខ្យល់

ក្រសែកគ្រសាយ អន្ទាយលុះដល់ ខ្ទឹមវិលវល់

ជ្រុលជ្រួសហួសទៅ ។

លង្គោចលង្គឹម លង្ងន់ស្ងួនស្ងឹម អណ្តែតលឿនស្ងៅ

មៀនមើលមិនជាក់ ដូចអ្នកប្រុសពៅ មកដល់លំនៅ

នៃខ្ញុំប្អូនស្រី ។

ប្អូនស្មោះក្នុងប្រាណ ប្អូនស្ម័គ្រគិតស្មាន បានរួមមេត្រី

និងអ្នកប្រុសស្ងួន ខ្ទឹមខ្លួនពិសី ពិសុទ្ធប្រិមប្រិយ



ពិសេសសោភា ។

មិនដឹងជាប្រាស ពីស្រីនិកស ខានឃើញមុខគ្នា

រលូតជាតិនេះ រលេះឃ្លាតឃ្លា រលូតអសារ

សោះសូន្យផង់អើយ ។

ទទួចិត្តា ចិត្តម្តេចថ្លស្សា អម្ទេះព្រះអើយ

ពីដើមបេះផ្សំ ផ្គុំផ្គុំជាត្រើយ ឥឡូវម្តេចឡើយ

លោមកផ្តាច់ផ្តែ ។

៦៦០– បើមិនផ្សំផ្គុំ គួរគិតគួរកុំ ប្រមាថរាយដេរ

ប្រទេចផ្កាសា ដៀលថាឲ្យគេ ទុកគិតទៅថៃ

ហៅចិត្តអប្រិយ ។

បើមិនការណិត ព្រះអើយគួរគិត អាសូរប្រណី

មេត្តាករុណា អនិច្ចាប្រុសខ្មី មិនគួរដេរស្តី

បណ្តាញរាយផង ។

អ្នកថ្លៃប្អូនអើយ ប្អូនគិតទៅហើយ ហៅក្តីមិនសម

អ្នកថ្លៃមោះមក រួសរកអញខ្ញុំ ទុកពុករាយជំ

គ្មានតាំងគ្មានឃាត់ ។

ពីនេះទៅហើយ អ្នកប្រុសប្អូនអើយ ម្ទើរសមសាត់ព្រាត់

នាំម្តាយនាំកូន ប្រពូនប្រពន្ធ ជ្រៀតជ្រែកប្រាកដ

ដូចកល់សត្វជាតុ ។

ទ បើសំណាង  យើងបានសួមសាង  ពិតពីបុព្វជាតិ
សូមអស់ទេវតា  រក្សាកុំឃ្លាត  កុំឲ្យកើតព្យាធិ
បៀតបៀនចិត្តា ។

៦៦៥– សូមជួយឲ្យបាន  យើងតាំងភាពប្រាណ  មូលមួយនឹងគ្នា
កុំឲ្យប្រែប្រាស  ខិតសង្វាតឃ្លា  សូមបានស្នេហា
លន់លុះខិតញ៉ាន ។

នាងផ្សងស្រេចហើយ  កើតទុក្ខពុំស្បើយ  ពិលាបប្រះប្រាណ
ព្រកកៀមរក  អួលអាក់ពុំក្សាន្ត  កែងកែវខាន
ពិតពុំល្ហែល្ហើយ ។

នាងទឹកទៀតថា  ឱរៀមស្នេហា  សំឡាញ់ប្អូនអើយ
ប្អូនខឹកស្អកស្អះ  ចំពោះជាក្រោយ  បើប្រាសអ្នកហើយ
ពុំបានមូលមេត្រ ។

ក្នុងជាតិនេះណា  អ្នកកុំខឹកថា  ប្អូនមានស៊ីក
សមប្អូនខិនក្សយ  ប្រលីយពិត ។  សូមសុំជួបជិត
ទៅជាគូទ្វៃ ។

ប្រែសជាទៃ  ក្នុងខ្ញុំនេះផ្ទៃ  ប្អូនគ្មានទិស្ស័យ
ចូលចិត្តចេតនា  ប្រាថ្នាកាថ  មិនមានអាល័យ

កាខ្សោះឡើយណា ។

៦៧០– នាងខឹកសព្វគ្រប់  ខនគន្ធសញ្ចប់  ក្រំក្រៀមកក្រា
ស្រន្តិកស្រងល់  ទៀងទល់ទុក្ខា  ណាអត់អាហារ
បរិភោគម្ដង ៗ ។

ហើយនាងសត្វា  បន់អស់ទេវតា  ទេព្រក្សនោះផង
គឹងអស់ឥន្ទព្រហ្ម  ចត្តមកខ្ទង  ជួយជាបត្តង
បង្គោលស្រីថៃ ។

នាងផ្សងសត្វា  បពិត្រទេវតា  អ្នកបិតនៅព្រៃ
សោឡសសគ្គឋាន  វិមានប្រពៃ  សូមលោកជួយជ័យ
ជួយជាពេជ្ញាណ ។

បើខ្ញុំបានជួន  បានជួបប្រុសស្ងួន  ជាគូបុព្វណា
សូមឲ្យខ្ញុំរស់  ជាមនុស្សមែនមាន  គេជះសីលទាន
ជៀងជួយការពារ ។

បើប្រាសប្រុសប្រាណ  ក្នុងជាតិនេះខាន  រួមរស់រូបា
សូមឲ្យខ្ញុំស្លាប់  ទៅតាប់ដូចថា  កុំរស់ឡើយណា
ជាមនុស្សលោកឡើយ ។

៦៧៥– នាងនាថសត្វា  ខឹកអស់ទេវតា  ដូច្នេះស្រេចហើយ
ទេវីនាងសោក  អមោក្សកតស្បើយ  អាហារជាក្រោយ

កុំបានគោក្ដា ។

នាងសោកកន្ទេង　សៅស្រែសស្រេង　សព្វទិនទិវា
ថមថយកំឡាំង　ស្គមស្គាំងកាយា　កាយឫទ្ធិជរា
ដល់ដួលឈឺថ្កាត់ ។

អស់ទាំងទាសី　មេនំសាវស្រី　ក៏លៀនផងទាត់
គ្នាទៅដំកប　សេដ្ឋីនោះថ្កាត់　ឲ្យដឹងសាសក្យ
ពីនាងកើតទុក្ខ ។

ទាសីម្នាក់នោះ　ចរចូលទៅផ្ទះ　ដំកបផុតុក
ថាបពិត្រម្ចាស់　ធីតាអផ្សុក　អត់ទាំងទឹកកក់
ចំណីអាហារ ។

ឯភោគសេដ្ឋី　បានស្ដាប់សំដី　មេធំហើយណា
ភ័យភ្ញាក់ថ្មើមក្ដុក　វិតក្កចិត្តា　ប្រាប់ភរិយាថា
នាងអើយឥឡូវ ។

៦៨០– កេសរមាលា　កូនស្ងួនពុំងា　អផ្សុកពេកពៅ
ពុំដឹងម្ដេចទេ　មាសមេចូលទៅ　បន់ស្រន់ក្រែងត្រូវ
អារក្សទេព្រក្ស ។

ឯនាងភរិយា　ឮប្ដីចរចា　ភិតភ័យភ្ញាភ្ញាក់
រហ៊ឹករហៃ　សរស្រែកសស្រាក　ញញ័រញញាក់

ខ្ញែកពុំសព្វផង ។

ហើយទើបសួរថា　ហៃស្ងួនពុំងា　ចូរនាងសាសង
ប្រាយប្រាប់មាតា　កាលគ្រានេះម្ដង　ឲ្យម្ដាយដឹងផង
ឱនឥតមើលស្រី ។

កូនកល្យាណ　នាងនឹកចង់បាន　របស់អ្វី ។
នាងប្រាប់ម្ដាយពាំ　ស្ងួនភ្ញាពិសី　ម្ដាយមិនក្រក្រី
រិះរកឲ្យបាន ។

ឬមួយកូនគង់　កូនតូចអាក់អន់　ទឹងខ្ញុំក្នុងឋាន
ក៏ស្ដីផ្ដេសផ្ដាស　ឲ្យមាសកល្យាណ　ឬមួយមាសមាន
ចិត្តចង់ទៅណា ។

៦៨៤– ស្ងួនកូនព្រលឹង　ប្រាប់ម្ដាយឲ្យដឹង　ឆាប់ ។ រួសរាក់
ម្ដាយនឹងគិតការ　ឲ្យបានដូចថា　ឬមួយមានគ្រោ-(១)
ការកើតកល់អ្វី ។

កាលនោះធីតា　កេសរមាលា　ប្រសើរស្រស់ស្រី
នាងស្ដាប់មាតា　សួរសារពោះវៃ　នាងរកសំដី
គិតកែមុសា ។

អ្នកម៉ែខ្ញុំអើយ　ខ្ញុំគ្មានគិតឡើយ　ទៅណាមកណា

---

១–តាមច្បាប់ គ្រោ តែនេះ សម្រួលតាមសព្ទសុភាព ។

មិនមានអាក់អន់ តូចតន់ចិត្ត ទីទ័ព្វកស្រីការ
ដល់ពិបទៀយហោង ។

មួយទៀតខ្ញុំគ្មាន បក្ខពិតពន់បាន ទ្រព្យធនក្សីផង
ខ្ញុំឈឺក្នុងខ្លួន ព្រួយព្រួនកន្លង ករខ្លួនសៅហ្មង
មិនមានល្ហែល្ហើយ ។

រឯបាយទឹក ខ្ញុំគ្មានបើនឹក ឃ្លានដល់ពិបទៀយ
ដូចជាបុកធ្លុល់ កាយកល់ល្វេងល្វើយ អ្នកម្តាយកូនអើយ
ខ្លួនកូននេះណា ។

២៩០– បើកៃបេះទៅ សមការបាននៅ ឃើញមុខមាតា
ម្តាយនាងបានស្តាប់ សាសព្ទពាក្យ ភិតភ័យតក្កមា
ពេកពន់កន្លង ។

ស្វាស្ទុះទៅមក រកទៀនធូបយក មកគុជជាម្ចាស់
ផ្ចាត់លើអង្គ បនបែក្រផង អង្វរក្រុផ្លង
សំពះថៃថា ។

ទ្រប្រាជ្ញាយ ចំប៉ូវតាំងឡាយ សូមលោកមេត្តា
ស្តោះព្រួសពោសផ្លុំ អស់ជម្ងឺណា ឲ្យពន្លឺតាបជា
ពីថ្ងៃនេះទៅ ។

ពីសាបខ្មោចខ្មាំង ពីក្រៅគន់ធាំង មានអស់លោកគ្រូ



បរៀះចៀសចេញ បណ្តេញរំពោ ឲ្យជ្រះព្រៃជ្រៅ
កុំឲ្យលាយឡំ ។

ឯនាងស្រីគន់ ស្តាប់ម្តាយបែរបន់ នាងធ្វើសម្ងំ
ម្តាយយល់កូនបាន ស្រាកស្រាន្តបន្តំ ផ្តាំអស់មេធំ
ក៏លៀនរក្សា ។

២៩៥– ហើយនាងចេញទ្ធី មកប្រាប់សេដ្ឋី ជាប្តីភគ្នា
និយាយរៀបរាប់ សព្វគ្រប់ប្រការ ដូចកាលវេលា
ប៉ុន្មានមកស្រាប់ ។

ឯលោកសេដ្ឋី បានដឹងសេចក្តី ប្រពន្ធប្រាយប្រាប់
គិតលៀនមេមក់ ផែលនុត ។ នាប់ ប្រើបាវប្រញាប់
រត់រកគ្រូនភ្ញាត់ ។

អ្នកខ្លះធ្វើពន បោកបាយស៊ីបាន មានតាំងយូរក្រ
ស្វាធមិទឹកអប់ ដាក់គ្រប់សក្កាត់ ណ្តាប់ប្រើនក្តាត់
ខ្លះរៀបគាក់តែង ។

សំពត់ពាក់កន តាំងធ្វេងស្តាំមាន តែរតៃពៃចង
ត្រីសាច់ញាំក្វា ធុរនាគ្រលែង រៀបគ្រប់ដំណែង
ដំណើរសែនលា ។

អ្នកខ្លះសោតរត់ ទៅរកមេមត់ បានមកម្ពីម្នា

លេងភ្លេងបញ្ចាន់ បន់ស្រន់បូជា មេមត់នោះរាំ
ចូលជាន់ឆាប់ខ្មី ។

៣០០– សាកសួរថៃថា ហៃអស់ជូនតា រកឃើញធ្វើអ្វី
កាលនោះអ្នកស្ងំ បង្គំហើយស្តី ថាលោកសេដ្ឋី
ឲ្យឃើញរកអ្នក ។

បុត្រកល្យាណ មិនសូវសុខសាន្ត ត្បិតមានធុរៈ
តើត្រូវកលអ្វី ចូរស្តីកុំលាក់ ប្រាប់ឃើញឲ្យជាក់
កាលគ្រានេះម្តង ។

មេមត់មើលដៃ មើលតាយបំភ័យ បំភ័ន្តសាសង
ថាតានជីតា បុត្រក្លាស្នេហ៍ស្នង ត្រូវកលគេហោង
ស្រូបព្រលឹងបាន ។

ហើយប្រើព្រាយមក ធ្វើទុក្ខសៀតសឹក ឲ្យឈឺខ្លួនប្រាណ
ឲ្យផុំបាយទឹក មិនឲ្យទឹកឃ្លាន ដូចោះមែនមាន
គួររៀបឲ្យបាយ ។

ហៅព្រាយចេញមក ឲ្យទទួលយក អាហារតាំងឡាយ
មនុស្សព្រួដូចោះ ស្នាស្ទុះប្រញាយ ត់រកស្រាបាយ
ត្រីសាច់ញាំភ្លា ។

៣០៥– ដាក់ពែហើយរៀប ខន្ធគ្រឿងសោត ប្រេងម្សៅគន្ធា



អុជទៀនអុជធូប ក្រអូបមហិមា លើកមកម្នា
ដាក់នៅមុខរាន ។

ហើយយកភ្លើងកែ មេមត់កាំរែ តប់លាដបាចបាន
ហើយស្រែកហៅព្រាយ រាយមាយមួយមាន ទើបឲ្យជូនពន
ជូនខ្មោចព្រៃទៅ ។

ហើយមេមត់ថា ខ្មោចចេញទៅណា អំពើរនៅ
ក្នុងអង្គធីតា បុត្រក្លាគោមគៅ រកថ្នាំផឹកទៅ
ទើបបានសះជា ។

មេមត់បញ្ចេញទៅ សេដ្ឋីនោះក្តី ឲ្យរកពេទ្យា
ដែលថ្លាប់ពូកែ មើលគេសព្វគ្រា រកបានហើយណា
នាំចូលមកឋាន ។

ដល់ផ្ទះសេដ្ឋី យល់ហើយហៅខ្ញី អន្ទុយប្រែប្រាណ
និយាយរៀបរាប់ ប្រាយប្រាប់ពតិមាន សូមជាថ្នាំបាន
ឲ្យទៅភរិយា ។

៣១០– យកទៅឲ្យនាង ដាំផឹកលាបលាង ខែអំពើរ
ភរិយាយកជូន ឲ្យកូនពុំផា បន្ទាប់អស់តា-
សីទ្វិកំដរ ។

ឲ្យដាំឲ្យនាង ផ្ទុតផឹកលាបលាង អំពើពុំល្អ

នាងពុតធ្វើស្រួល ទទួលស្មោះសារ សំពះហើយយក
ផ្កាំនោះទុកនៅ ។

ឯនាងមាតា ផ្តាំស្រេចហើយណា ក្រោកដើរមកក្រៅ
អន្ទុយតាមប្តី ស្រដីមកទៅ ឯបុត្រស្រីពៅ
ពីក្រោយមាតា ។

តែងទល់ទុក្ខក្តៅ ស្រងល់ស្រងៅ ស្រងូតក្រៀ
សញ្ចប់សញ្ចឹង រើងវៃថា ឱះឱកាលណា
នាងនឹងបានស្បើយ ។

សេដ្ឋីបិតា ជាវៃផ្ទាំពេទ្យ ច្រើនក្រៃជាត្រើយ
បង្អាតប៉ុន្មាន មិនមានស្តាយឡើយ តែងចិញ្ចរឿយ
រៀងរាល់ខែឆ្នាំ ។

៣១៩– នាងនាថទេវី ពិតពង្សពោធិ៍ រកៀសកាំ
កន្ទេងខ្លោចផ្សា ទុកក្រៀមក្រំ សោះនៅរង់ចាំ
ជួបជួនកស្តា ។

លង់លុះគ្រាន់គ្រប់ ប្រាំមួយដណ្តប់ ឆ្នាំហើយតិតថា
ធ្វើម្តេចបានជួន ប្រុសស្ងួនស្នេហា ចង់ទៅលេងផ្សារ
ក្រែងបានជួបអ្នក ។

នាងគិតហោះហើយ ក្រោកអរឥតស្បើយ ក្នុងចិត្តស្មោះស្មើគ្រ



ហើយនាងនីតា លាលុំចេញជាក់ ស្រីផងតគ្រាក់
គគ្រឹកតាមទៅ ។

បានជល់ឪពុក ទុនអន្ទុយប៉ុក ក្រញ្ញុក្រោបស្ងៀមនោះ
សេដ្ឋីយល់បុត្រ ពិសុទ្ធល្អញល្អ មកជួខ្លះកូវ
ដណ្តឹងវៃថា ។

ហៃហៅនាងកូនស្ងួន ពន្ធកខ្ទើមខ្លួន សំឡាញ់បិតា
នាងមករកឪ កូនស្រីចរចារ ប្រាប់ឪពុកកំ
មាសឪពុកអើយ ។

៣២០– កេសរមាលា ស្តាប់ពាក្យបិតា ស្ងួរជូខ្លះហើយ
នាងឱនអន្ទកាយ និយាយគ្នាស់ឆ្លើយ ថាអ្នកឪអើយ
ស្តាប់កូនចរចា ។

បើឪគាណិក ឲ្យរស់ជីវិត មែនមានជន្មា
ចិត្តខ្ញុំកូនពៅ ចង់ទៅលេងផ្សារ មៀនមើលអស់មហា-
ជនចូលចិញ្ជួរ ។

ក្រែងគ្រាន់សាយ អស់កោតខាំងឡាយ ក្បេមក្បាន្តបានឆ្ងួរ
ដោយចិត្តសប្បាយ ឪងគិតនឹងគួរ អ្នកឪគាស្ងួរ
ឲ្យទុកកូនស្បើយ ។

សេដ្ឋីបិតា ឮដូច្នោះថា ម្តាយឪពុកអើយ

កុំទាលក់ផ្លាស់ ខ្មាសគេគួរអើយ កំឡុងទៅហើយ
អាក្រក់កេរ្តិ៍ឆ្ងាយ ។

នាងស្តាប់ឪពុក ថ្លោះហើយកើតទុក្ខ ទោមនស្សក្នុងកាយ
នាងសោយសោកា ថ្លែងថាខ្លួនកាយ សមស្លាប់អន្តរាយ
ថ្ងៃនេះថ្ងៃស្អែក ។

៣២៥ ទុកតទៅគ្រប់ ថប់ហើយវែងថប់ នឹងខ្លួនពន់ពេក
កើតទុក្ខធ្ងន់ធ្ងន់ ព្រួយព្រួនអនេក អនន្តចំឡែក
លើសគេទាំងឡាយ ។

សេដ្ឋីយល់យល់ នាងនាថនិមិល ក្ដួចគន់ដោយឆាយ
នាងសោយសោកា លោមថាស្ងួនកាយ កូនកុំសោកស្ដាយ
សឹមមួយឲ្យទៅ ។

តែនាងឈប់សិន ត្រូវតែកឲ្យជ្អិន ចាំមុំជូនទៅ
នាងស្ដាប់បិតា លោមថាថ្លោះកូវ ទៅនៃតាមទៀ
បង្ហារសោកា ។

នាងលើកហត្ថា សំពះបិតា មាតាថ្លៃថ្លា
ហើយសឹងក្រោកអរ សាទរចិត្ត កាលនោះឯមហា
សេដ្ឋីឲ្យហៅ ។

ចិនជាមេការ អស់បាវម្ចាស់ រួសរាន់ទៅកៅ



ស្អាតគ្នាគ្រប់ប្រាក គ្រប់ល្អកនិត្យនៅ អាហាកិតុនថៅ(១)
ទៅផ្ទះលោកឆាប់ ។

៣៣០ ឯចិនមេការ ឮហើយម្ចាស់ ស្ទាស្ទុះប្រញាប់
ស្លៀកពាក់ខោអាវ ប្រញិបប្រញាប់ ដើរលឿនឆាប់ៗ
បន្តិចទៅដល់ ។

ឡើងទៅលើផ្ទះ ក្រាបក្រួញសំពះ ទូនអង្គកាយកល់
សេដ្ឋីសោមនស្ស ថ្វីខ្លះខ្វាយខ្វល់ ឥតមានទោសទាល់
ទៀបនឹងអាត្មា ។

ចិនសោកសួរទៅ សេដ្ឋីនិត្យទៅ ទីជិតអាត្មា
សេដ្ឋីស្ងួនស្ដាប់ សព្វគ្រប់វាចា ឆ្លាស់ឆ្លើយទៅថា
អញឲ្យហៅឯង ។

ជាមេការឈើ មកនឹងជួលធ្វើ ផ្ទះធំបីល្វែង
ធ្វើជាផ្ទះផ្សារ ជួរតាខេខ្នង តើអស់ពួកឯង
យកឈ្នួលប៉ុន្មាន ។

ចិនឆាយហ៊ូ(២)ថា ខ្ញុំជួលសព្វគ្រា បីល្វែងនោះបាន
តែប្រាំយបាទ ខ្ញុំឃាតការមាន សេដ្ឋីឆ្លើយថ្កាន

---

១ ពាក្យចិន = អ្នកធំ ។

២ ពាក្យចិន = អ្នកត្រួតត្រា អ្នកកត់បញ្ជី ។

អញឲ្យតាមចៃ(១) ។

៥៩៥– ឯងធ្វើឲ្យដាច់ ស្រែកប្រញាប់ រវៀសរវៃ
ធ្វើក្រឆឹងដើមផ្ការ ប្រែបញ្ចារនោះនៃ ក្រវិចក្ដមខ្ញុំស្បៃក្រ
ពោមកោមគ្រប់គ្នា ។

## បទពំនោល

៦០០- បទពំនោលនូវពណ៌នា ឯចិនមេការ កាលណាបើបានដើរដល់ ។
គ្រឹហារហៅគ្នារវល់ ព្រាយព្រាប់ការកល សាយសព្វគ្រប់គ្នាពុំខាន ។
ប្រដាប់ដីដៃដែកគ្រប់ប្រាណ ប្រុងប្រៀបមិនមាន ភាគភាពខ្វះកន្ទះឡើយ ។
គួសឈើសារពើមកហើយ គរទុកជាត្រើយ ចាត់ចែងតែងដាក់មុខគ្នា ។
ខ្វះចាំងសសរសោះសា ខ្វះសោតអាស្ការ ត្រាលក្របនូវគេកាល់ ។
៦០៥– ខ្វះកាយគោះដាប់របល់ ខ្វះរៀបផ្ទិកល់ តិកកៃក្បៀកក្បាច់ពេជ្រផង ។
អាប្រាបផ្កាផ្គានបន្ទន់ ប្រុងប្រៀបពុំលង់ ដីការណ្ដៅងាំសសរ ។
តម្រង់ត្រឹមត្រង់ត្រៀល្អ ដាក់គេកយ៉- នូវគោះដែកគោលក្រាលក្ដារ ។
ពាក់ផ្កាផ្គងផ្កានហើយណា ពិទួលពិទូរ យោងមេដំបូលដល់ដាក់ ។
គោះដែកផ្កាផ្កានតាមដាក់ ត្រឹមត្រង់សន្ធាក់ ហើយលាបបន្តង់ស្រស់ស្រាប់ ។
៦១០ ប្រក់ក្បឿងរុងរឿងចំណាប់ ប្តូកបាយអស្ចារ្យ យកមកធ្វើជាជញ្ជាំង ។
ធ្វើទ្វារនុករុកពាំង គន្ធឹះឃាត់ឃាំង ប្រយែងប្រយ័ត្នគេកក្រ ។

១– ពាក្យសៀម ខ្មែរថា ចិត្ត ។



ធ្វើរបស្រាប់ស្រេចហើយនៃ នាំគ្នាវៃលៃ វិលវិញទៅហៅនាគា ។
ឯនាយហ៊ូមេការ ចូលដំណឹងមហា- សេដ្ឋីថាទះលោកអើយ ។
ខ្ញុំបាទសង់ផ្ទះរួចហើយ មិនមានខានឡើយ សូមបានប្រាក់ពីគុនទៅ ។
៦១៥- សេដ្ឋីឮហើយទៅពៅ ប្រើបាវគេស្ទៅ ទៅហៅនូវអ្នកនាយឃ្លាំង ។
ទៅនោះគេស្ទុះក្ដួងគាំង សារខ្លួនក្ដោះខ្ទាំង គ្មានហត់ហបឡើយណា ។
ដល់ទៅស្រែកហៅប្រាប់ថា អ្នកឃ្លាំងលោកមហា- សេដ្ឋីឲ្យហៅនាប់ៗ ។
ឯនាយឃ្លាំងបានស្ដាប់ រៀបខ្លួនប្រញាប់ ចរចុះរួសរាន់គេទៅ ។
ដល់ហើយទទួលអញ្ជើយនៅ សេដ្ឋីក្រឡៅ ក្រឡេករមិលមើលដាក់ ។
៦២០-ហើយថាអាក់យកប្រាក់ ថ្លៃឈើនជៀងជាក់ ពាក់ពានមកឲ្យនាយហ៊ូ ។
ទៅចុះនាប់ឡើងគុំយូរ នឹងកាលគិតគូរ គេចាញ់ចំពាញដាក់ផ្ការ ។
នាយឃ្លាំងទទួលក្រាបលា ទៅរយាត្រា ផលឃ្លាំងចាក់សោយកប្រាក់ ។
រាប់បានថ្លៃឈើនជាក់លាក់ យកផងពានដាក់ កាន់ដើរលើលើចុះទៅ ។
លីលាយាត្រាតាមផ្លូវ ក្រាបគាត់សំពៅ ដល់ហើយលើកជូនសេដ្ឋី ។
៦២៥- រាប់គ្រាប់គ្រប់ថ្លៃ ប្រគល់ទៅខ្មី ឲ្យចិននាយហ៊ូហើយណា ។
កាលនោះឯចិនមេការ សំពះលាមហា- សេដ្ឋីទៅផ្ទះនៃខ្លួន ។
ហៅគ្នាមកគ្រប់ចំនួន គិតគ្នានៅជួន រាប់ប្រាក់ចាត់ចែកគ្នីគ្នា ។
ខ្វះទិញកាក្លៀនទិញស្រា ខ្វះទិញកញ្ឆា ទិញមាន់ទិញមីស៊ីផឹក ។
ខ្វះលេងល្បែងបៀពុំទីក មួយយប់ទល់ព្រឹក គ្មានគង់កាសមួយទៅផ្ទះ ។

ព្រោះតែខ្ញុំបង់ឈ្នះ ពាល់តែស្រឡះ រលីងយង់តង់តែវា ។
គ្លួតខ្នុះឡើតឡើបញ្ចារ ហិតហាំនេះហោ តាក់ព្យួរដៃជំពីជា ។
ចិនថ្លៃសំដែនកាលគ្រោ កាលក្រោយចំនលោ ឯមហាសេដ្ឋីឯងកាប ។
ប្រើបាវប្រើព្រាវខ្ញុំឃ្លាត រួសរត់សង្វាត រកចិញ្ចឹមចិញ្ចាំទាំងឡាយ ។
ចិញ្ចឹមហ្លួលចិញ្ចាំព្រៃប្រញាយ ចិញ្ចឹមលំក្តៅលឿងស្វាយ បៃតងក្រហមទៀតទឹម ។
ចិញ្ចឹមទៀនសន្ទៀនសន្ទឹម ចិញ្ចឹមម្រេចចិញ្ចឹមខ្ទឹម ចំប៉ាំន(១)ម្សៅហាវប៉ូបកាក់ ។
ចិញ្ចឹមគ្រឿងបង្ហៃចិញ្ចឹមដាក់ ចិញ្ចឹមតាំងពានស្រាក់ កន្តោរទឹកកាតុផាស ។
ចិញ្ចឹមសព្វគ្រាប់គ្រប់ពារពាស គ្រឿងតាម៉ីនគ្រឿងរាស្ត្រ មិនមានខ្វះខាតអ្វីឡើយ ។
ផញ្ជូនដាក់ផ្ទះស្រេចហើយ រៀបចំដាក់ត្រើយ ជួបដោយចំណាំផ្ទះផ្សារ ។
ហើយវាក់ឆ្នាំឲ្យញាប់ញាល ខ្វះឲ្យយាត្រា ចូលទៅផ្តកបសេដ្ឋី ។
ដល់ហើយក្រញូវក្រាបសំរើ ផ្តកបសេដ្ឋី ថាខ្ញុំចិញ្ចឹមចិញ្ចាំផង ។
សព្វគ្រប់គ្រប់ខ្វះជាម្តង សេដ្ឋីធ្វើយធ្ងន់ សួរថាចិញ្ចឹមអស់ប៉ុន្មាន ។
នាយឃ្លាំងបើកបញ្ជីបាន ដឹងហើយឆ្លើយប្រាប់ ថាចិញ្ចឹមអស់ណែនមួយពាន់
ទ្រព្យធួនសំនួនក្រែលគ្រាន់ សព្វគ្រប់ពីរពាន់ ល្មមនឹងលក់ផ្សារហើយណា ។
សេដ្ឋីស្តែនស្តាប់រាំថា នាយឃ្លាំងថែថា គ្រោកអរក្នុងចិត្តឥតសង្ស័យ ។
ហៅខ្ញុំមកជុំដាក់ត្រើយ ប្រាប់ថាហងអើយ ទៅប្រាប់ប្អូនកែវកល្យាណ ។
ឲ្យនាងរួសរៀបខ្លួនប្រាណ នឹងតាលចេញស្ថាន ទៅលក់ផ្សារអស់ពីរពាន់ ។

១-ពាក្យចំន ម្សៅសម្រាប់លាងគ្រឿងប្រើប្រាស់ ។



ពាសីស្តាប់ហើយឃ្លាតឃ្លាន លុតលារួសរាន់ ចរចូលផ្តកបឆិកា ។
ដល់ហើយក្រញូវក្រាបសំរេស ផ្តកបថែថា បពិត្រអ្នកម្ចាស់ខ្ញុំអើយ ។
ប្រសាសន៍លោកតាដាក់ត្រើយ ប្រើខ្ញុំមកហើយ ផ្តកបអ្នកម្ចាស់ទោះធាយ ។
ឲ្យរៀបប្រដាប់ប្រៀបអង្គកាយ ប្រាប់ឈាមទាំងឡាយ ឲ្យរៀបខ្លួនទៅដាក់ផ្សារ។
ទេវីស្រស់ស្រីផឹត បានស្តាប់រាំថា ពាសីផ្តកបប្លោះហើយ ។
អរឯងឥតឯងថ្លឹមឡើយ និកថាអញអើយ អញបានជួបភ្នាន(១)ប្រាថ្នា ។
ហើយតាន់ចូលថ្លុកគគ្គា ពិចិត្រផ្កា អប់សិងសុគន្ធាធរ ។
ក្លាយខ្ញុំនក្រសួបខ្លាយខ្លួរ ថ្លុតស្រេចលាបរ- មៀតឡើងពណ៌លឿងរៃមទាយ។
លាបស្រេចលេបចេញតែងកាយ សំពត់សាសាយ លាបប្រេងក្រមួនខាប់ខ្មៅ ។
កន្ត្រាផ្សារផង់ដាក់មេ្យ៉ាង ស្រេចស្រស់នោមខ្មៅ ពាប់យកសំពត់សម្ពិម ។
យ៉ាងឯកក្បូវថ្លុកឥតថ្លឹម មកស្លៀកគម្រើម កម្រវក្រវចិត្តនោមយង់ ។
ពាក់អាវប៉ាក់ចៅទឹងល្អង លេចផ្កាលង់ រលើបរលោងលឿងទុំ ។
បំនបាវយ៉ាងក្រាស់ដាហិម មៀងមើលស័ក្តិសម ស្រគំស្រគត់គួរគាប់ ។
ចំហូត្បូងពេជ្រតាំងគ្រាប់ មាសឆ្អិនទឹកជប់ នឹងកប៉ារៈថ្លៃកុំបាន ។
បំពាក់ត្បូងពេជ្រសូរ្យកាន្ត ថ្លៃឥតប្រមាណ កល្យាណពាក់គ្រប់ទាំងម្រាម ។
ខ្សែដៃត្បូងពេជ្រពក្វាម ពាក់ពួកលលាម ទទឹមមរកតពេជ្រល្អ ។
ដាសដាំចំរុះបញ្ចពណ៌ សម្ពង់ទៀតស ពៃលមលឿងប្រាកព្រោងប្រាលប្រាល ។

១–ពាក្យបុកណា = បំណង ។

ខ្សែខ្លួនមាសឆ្អិនឆ្នោល ទេវីសាល តាំងរៀបខ្លួនស្រេចហើយណា ។
ហៅស្រីតាស៊ីបរិវារ សម្រាប់គ្នា ឲ្យរៀបចំខ្លួនទាំងខ ។
អស់ខ្ញុំកុះកុំច្រើនក្រៃ មូលមកពេញៗ ប្រាសាទប្រសើរសោភា ។
តែងតួស្មៀតពាក់គ្រប់គ្នា ចរចេញលីលា មកជុំនៅក្រៅហើយណា ។
សេដ្ឋីមាតាបិតា សឹងរៀបគ្នា នឹងជូនបុត្រពៅទៅខ្មី ។
ស័ព្ទបរិការប្រុសស្រី ចាស់ៗនោះនៃ ឲ្យនៅចាំផ្ទះសម្បែង ។
ស្រេចហើយសេដ្ឋីតាត់តែង ឲ្យរៀបគ្រែសែង ទាំងបីបានហើយលីលា ។
ព្រមអស់ពពួកបរិពារ ហៃហោមអមមហា- សេដ្ឋីទៅដល់ហើយហោង ។
ចរចូលក្នុងផ្ទះជាម្តង រៀបចំមិញផង ផ្គងលើកថ្វាយបិតា ។
សេដ្ឋីស្រដីទៅថា កូននឹងគ្នា ជាម្ចាស់កូនកែវឪពុក ។
នាងនឹងយកខ្ញុំណាទុក គ្រាន់ឲ្យជួយលក់ ថែចាំរបស់ធនធាន ។
ឯអង្គនាងយល់អ្នកឈាន ឥនអង្គប្រួញប្រាណ សំពះសេដ្ឋីបិតា ។
ថាខ្ញុំសុំទុកបរិវារ ប្រាំបីនាក់ណា ទំនុកទុកចិត្តនៃខ្ញុំ ។
ហើយនាងរើសស្រីក្រមុំ មានរូបល័ក្ខលម សឹករបេះកាសលាស់ខ្លួន ។
បេះចាមបេះចិនបេះយួន បេះសៀមសំខួន លាវកាវក្លួយពារផ្កាក្តិ ។
បេះគ្រប់ភាសាផ្សេងៗ មកទិញជូរជើង មិនអាចផុងខ្លួនបានឡើយ ។
នាងជ្រើសរើសបានគ្រប់ហើយ ក្នុងចិត្តហាក់ស្បើយ ប្រមាណមុខជាឪ្យប្ដី។
កាលនោះឯអង្គសេដ្ឋី វែកញាំបុត្រី ហើយនាំភរិយាទៅផ្ទះ ។



ទឹកអរក្នុងចិត្តពេកណាស់ ភ្ញុំមុត្រចាមជ្រះ ស្រវ្រះព្យាធិរោគា ។
ល្ងាចៗ តែងតែលីលា ទទួលបុត្រា យកទៅទីព្រាគ្រឹះស្ថាន ។
ព្រឹកឡើងទើបជូនមកប្ដាន សព្វថ្ងៃមិនមាន ខានខានគិលម្ដួយវេលា ។

## បទកាកគតិ

ថែរបទកាកកាល នាងនាថវិសាល វិសេសសោភា
នាងមកជាក់តាន ធនធានជា១ កាលនោះមនុស្សា
ចូលមកអឹងកង ។

កាន់ប្រាក់កាន់កាស់ មីរមករពេញពាស ចូលទិញទ្រព្យផង
ផ្សំនឹងចង់មើល រូបរក្សាស្នេហ៍ស្នង នាងល្អកន្ទង
លើសលែងនានា ។

ស្រីប្រុសចាស់ទុំ កំឡោះក្រមុំ ស្រុកស្រែចំការ
មូលមកទិញផ្ការ ទិញម្ទូទិញស្លា ខ្លះទិញក្រមា
បារីបារាំង ។

ខ្លះទិញនំនែក ដំណាប់សាវណ្ណក នំពាំងប័ុង
អ្នកខ្លះទិញចាន ជើងក្រានទិញឆ្នាំង ខ្លះទិញគ្រឿងតាំង
គ្រឿងទេសតាំងក្បាយ ។

ខ្លះទិញអម្បោះ កប៉ូរប្រេងក្រោះ ទិញល័ក្ខលៀងស្វាយ
ទិញក្រាសកញ្ចក់ ឆ្នុះមុខឃើញស្អាយ ទិញភ្ញៀសហាយ

មិនឲ្យពាក់ចិត្ត ។

ខ្ទះចិញ្ចើមផ្ទាប់ ក្រមួនពាត់ស្រោប ក្រអូបពេកពិត
ចិញ្ចើមស្រៀបចំគន្លង ចិញ្ចើមកូនកាំបិត អ្នកខ្ទះចិញ្ចើមស្និត
ស៊ិតកេសាសាយ ។

ឯនាងនិមិល បងដឹងកិច្ចកល ពីរៀបតោមតាយ
សួរសាប្រស្រីយ ថ្ពាល់ថ្ងៃអ្នកកាយ អ្នកនៅជិតឆ្ងាយ
បងប្អូនកល់គ្នា ។

ក្រែងឃើញអ្នកខ្សត់ លំបាកទុគ៌ត កូនចិនមាតា
តែងដើរសូមទាន ភាគកលផ្សារ ឥឡូវនេះណា
អ្នកបានឃើញផង ។

ឯអ្នកផងឡើយ ជាអ្នកនាងអើយ កុំឃើញឡើយហោង
តែផ្ទាំមុខមាន បានឃើញច្រើនផង តែងដើរហោង
សូមទានជោយផ្សារ ។

១៤៩ ឥឡូវបាត់ឈឹង សោះសូន្យកុំដឹង ជាទៅឯណា
នាងឮអ្នកហោះ អោះអុះចិន្តា គឺងក្ដីទុក
កើតទុក្ខកុំស្បើយ ។

នឹកក្ដីចិន្តា ឲ្យប្រុសស្នេហា បុកណាប្អូនអើយ
អ្នកតាំមាតា ទៅណាទៅហើយ ប្អូនមិនដឹងឡើយ

ប្អូនរងទុក្ខតាំ ។

យូរលង់ណាស់ហើយ ទុក្ខប្អូនកុំស្បើយ រៀងកល់តែឆ្នាំ
ឥឡូវប្អូនមក រិះរកគយឃ្មាំ មើលផ្លូវទំពាំ
អ្នកប្រុសប្អូនដល់ ។

នាងតែងគន់គិត រំពាន់ក្ដីចិត្ត រសាប់រសល់
រសេះរសោះ ខន់អស់កាយពល ខ្វល់គប់ច្របល់
ស្មើគ្បើយជាមួន ។

ទៅក្បែរថ្ងៃ សួរគេសព្វថ្ងៃ គ្មានសល់ឡើយហោង
នាងប្រើប្រាជ្ញា ផ្ញើជាសាសន៍ និយាយទៅផង
នីងអ្នកនានា ។

៣៥០-អ្នកអើយខ្ញុំគិត មានចិត្តអាណិត អនាថអនិច្ចា
អ្នកខ្សត់ហិនហោច ត្រមោចកំព្រា បងឲ្យទានគ្នា
ជាទ្រព្យអ្វីៗ ។

ជូនថ្ងៃមួយណា មានសិស្សអាចារ្យ ជាកូនមន្ត្រី
លីលាមកដល់ មណ្ឌលនាងខ្ញី ចូលចិញ្ចបារី
បាកំងយ៉ាងធំ ។

ដាក់ក្នុងហោប៉ៅ គួរវែកគូសនៅ ជក់ហុយដង្គំ
ដើរលេងគគ្រឹក ឆ្សៀកឯងធំ ដើរលេងលាយខ្ញុំ

មុខផ្ទះនាងណា ។

លុះឮនាងស្តី ផ្ទះនោះហើយខ្ញុំ ភ្ញាស់ឆ្លើយទៅថា
បើនាងឲ្យទាន ចង់បានផលា កូនសិស្សអាចារ្យ
មួយនោះក្រៃក្រ ។

កំព្រាកំព្រា គ្មានញាតិកា ទីពឹងគេឡើយនៃ
មកពីស្រុកឆ្ងាយ ទីដ៏ឆ្ងាយឃ្លាឃ្លៃ ម្តាយសោកកំសួយ
នៅតែម្នាក់ឯង ។

៣៥៩–មកនៅដោយសារ ទីពឹងលោកគ្រូ លោកប្រើឥតក្រែង
គ្មានបានរៀនសូត្រ រៀនសោះតែង ប្រើតាំងពីក្មេង
គ្មានខ្វះក្បាលមួយ ។

សំពត់មួយចាស់ កណ្តាបចំណាះ ពុកផុយល្អួយ
ពីរដណ្តប់ឆ្នាំ ព្រាំស្បៀកតែមួយ ខ្ញុំមើលទៅព្រួយ
ចិត្តជួសសព្វថ្ងៃ ។

បើនាងមេត្តា ឲ្យអ្នកនោះណា សមបានបុណ្យក្រៃ
ក្សត់គ្នាកំសត់ ទុគ៌តហិនហៃ បើបានអាស្រ័យ
សមអរពេកណាស់ ។

នាងស្តាប់ហើយណា ត្រេកសោមនស្សា ពន់ពេកក្រៃក្រាស់
នេះសមរៀមរក្ស ប្រាកដជាក់ច្បាស់ មកនៅទីផ្ទះ

អាចារ្យនោះនៃ ។

យល់មែនមិនឃ្លៀង មិនមានជ្រៅជ្រៀង ឯទៀតដទៃ
ប្រាកដជាអ្នក វិលក្ខណ៍ប្រពៃ ប្អូនអរប្អូនភ័យ
ក្រែងមែនមិនមែន ។

៣៦០–ទើបនាងធីតា គិតក្នុងប្រាជ្ញា ដនៃវៃក្មេន
ប្រាជ្ញប្រាយសុសសព្វ គ្រាន់គ្រប់សល់សែន ឆ្លើយថាហ្នោះមែន
នាំមកឲ្យខ្ញុំ ។

ទីងបានឲ្យទាន មាសប្រាក់ធនធាន ហូលព្រែផាហ៊ុម
នូវអស់អាហារ ពិសាសួស្តីសម បើអ្នកបាននាំ
មកដល់ផ្ទួចថា ។

ខ្ញុំឲ្យរង្វាន់ ឲ្យបានគ្រប់គ្រាន់ ពេញចិត្តចិន្តា
សំពត់ហូលផរ អាវខ្សាព្រែផ្កា ផាហ៊ុមយ៉ាងជា
មានឆត្រស្បែកជើង ។

បុរសនោះឆ្លើយ ថាហៃនាងអើយ នោះទុកវារយើង
នាងថាបើហ្នោះ ទៅចុះឆាប់ឡើង រៀសរៃដើង
នាំមកឲ្យឆាប់ ។

បុរសនោះលា នាងទៅម្ដីម្នា ស្រូតរូតប្រញាប់
បានដល់ហើយណា ល័លាឡើងឆាប់ អង្គុយផ្ទឹមផ្ទាប់

ចិនសេដ្ឋីបុត្រ ។

៣៦៨- ខ្សឹបខ្សៀវប្រាប់ប្រាយ ស្រទបបេកអាយ ទៅយកសំពត់
នាងកូនសេដ្ឋី ពិសីពិសុទ្ធ គេឆ្អកខុតិត
គេចិនឲ្យទាន ។

សេដ្ឋីបុត្រឆ្លើយ ថាហៃអ្នកអើយ ខ្ញុំមិនគួរមាន
សំពត់ល្អល្អះ ល្បឿនណាស់លើសប្រាណ ខ្ញុំបួសមិនបាន
ទៅទេអ្នកអើយ ។

បុរសនោះថា ឯងស្តីនោះណា ពុំត្រូវសោះឡើយ
គេឲ្យទានទេ ម្តេចវេរគោះតើយ មកទៅតាអើយ
អញនាំទៅយក ។

មិនថាតែមាត់ ដៃលូកចាប់ហត្ថ ពោធិពទូក
ប្រឹងទាញទន់អ្នក កន្ត្រាក់ទួសក្រោក ស្រដីតហក
ក៏ហានដេរថា ។

តាខូចខែមុខ កំប្រឹងកំប្រេក កំក្រោនដូចស្វា
មមីមមើ ពាក្យលេលា ដូចក្លួតពុទ្យា
មិនដឹងក្បាលខ្លួញ ។

៣៧០- គេហៅឲ្យទៅ យកសំពត់តា ប្រែជាខ្ពែរត្អូញ
ថានោះថានេះ ស្រមេះស្រមួញ ធ្វើមុខដូរហួញ



ដូចខ្មោចពេះណា ។

ពោធិសត្វស្រែក ប្រកួតប្រកែក ពុំទៅសោះសា
បុរសនោះទាញ អ្នកក្រាញញោក ពួជល់អាចារ្យ
ចេញមកឆាប់ខ្មី ។

ស្រែកសួរទៅថា ដូចម្តេចតើអា ទន់ទាញកថ្មី
មានកិច្ចមានកេខ មានហេតុកលអ្វី ម្តេចមិនស្រដី
ឲ្យអញបានដឹង ។

តាឯងអស់នេះ ធ្វើយ៉ាងដូច្នេះ ហៅឥតបំណើង
បន្តិចអញឲ្យ រាំទៅលើវែង មុខតាឯងហ្នឹង
មិនឈ្នះវាទេ ។

បុរសនោះណា ល្មះឮអាចារ្យ បន្ទោសដូសដេរ
លុំលុកផង្គង់ ផាក់អង្គុយ លើកហត្ថទាំងទ្វេ
សំពះអាចារ្យ ។

៣៧៥- ដំកបទៅខ្មី ថាគ្មានហេតុអ្វី ទេលោកគ្រូតា
បានជាខ្ញុំបាទ សង្កាត់ម្ទេះណា ក្បែកមានមេត្តា
តាសួររាក្រៃ ។

នាំទៅយកទាន ក្បែកគេអ្នកមាន ចិត្តជាប្រពៃ
គេផ្តាំខ្ញុំថា ខុតិតហានវៃ គេចិនប្រស្រីយ

ធ្វើបុណ្យឲ្យទាន ។

គេសួរខ្ញុំថា មានអ្នកឯណា ឲ្យកទ្រព្យធនធាន
ខ្ញុំបាទបានប្រាប់ សាសព្ទពតិមាន គេជឿដោយដាន
គេផ្តាំខ្ញុំថា ។

ឲ្យនាំយកទៅ ឲ្យដល់លំនៅ នៃគេនោះណា
គេនឹងឲ្យទាន តាមប្រាណប្រាថ្នា ដល់បរលោកគា
ពាក្យពិតប្រពៃ ។

អាចារ្យបានស្តាប់ សិស្សដំរាបប្រាប់ ហើយឆ្លើយវៃវៃ
ថាបើដូច្នោះ ទៅចុះកុំភ័យ ឥតមានទោសពៃរ៍
ទេទៅកុំខាន ។

៣៨០– ពោធិសត្វ ស្តាប់ពាក្យអាចារ្យ បង្គាប់ប្រើប្រាណ
អ្នកក្រាបសំពះ ឆ្លើយឆ្លាស់ទៅថ្កាន ថាខ្ញុំមិនហ៊ាន
ទៅទេលោកតា ។

រូបនៃខ្ញុំ ស្លៀកល្អមិនសម លឿនលើសគ្នា
ម្តងនេះគេឲ្យ ចុះក្រោយនរណា គេនឹងមេត្តា
ឲ្យឯងញយ ១ ។

អំពុតកុំយក របស់គេមក ឲ្យមានកេរ្តិ៍ក្រោយ
មុខឯងដូចផ្អក គេឲ្យរកគេឡោយ គេផ្តាះផ្តួនឲ្យ



កើតខ្មាស់គេក្រៃ ។

ឯអាចារ្យឆ្លើយ មិនស្លៀកក៏ហើយ យកមកកែកៃ
លក់យកកាសប្រាក់ ទុកដាក់សំបៃ ចិញ្ចឹមអាស្រ័យ
ថ្ងៃយប់នឹងគេ ។

ពន្លកពុទ្ធញាណ ពិតពុំហ៊ានខាន ខ្លាចអាចារ្យជេរ
ដាលដោះឡើងគូ ដើរទៅតាមគេ គិតរកកល់កែ
មិនចង់ទៅឡើយ ។

៣៨៥– បុរសជួជាតិ តែងតួហួសមាឌ បីដូចមិនឆ្លើយ
ឲ្យពោធិសត្វ កាន់ធ្រេកតាមហើយ ឯងធ្វើព្រងើយ
ហាក់ឯងនាយកាយ ។

ចង់ប្រាយក្លួនក្លាច ឯងកាចអាចខ្លាច មើលនាយមើលអាយ
នាំពោធិសត្វ បុរសនោមឆាយ មនុស្សផងសើចសាយ
ព្រហ៊ឹងអឹងកង ។

ឯពង្សពុទ្ធា អ្នកទឹកអធិដ្ឋា ខ្ញុំនរកោកកូន
ទុះហោតុតែគ្មាន ផនធានឡើយហោង ទំនើងអ្នកផង
ធ្វើម្តេច ១ បាន ។

ល្ហើយចុះតាមកម្ម ពីព្រេងនាយនាំ អំពីបុរាណ
មកផ្តុញមកផ្តាល់ ឲ្យដល់អន្តប្រាណ ឲ្យក្របមាណ

ក្រមើលមិនយល់ ។

អ្នកទៅតាំងទុក្ខ ខ្មាសអស់អ្នកស្រុក សែនសល់មណ្ឌល
បុរសនាំថ្កាន ដល់ឋាននិមល ពោធិមណ្ឌល
នឹកក្នុងចិត្តា ។

៣៩០– អញកុំចូលទៅ ក្នុងផ្ទះគេគូរ ក្រែងគេថាជា
អ្នកតិតម្ទោះបាន ប្រែប្រាណយាត្រា អង្គុយក្បែរផ្សារ
មុខផ្ទះនាងនោះ ។

បុរសចូលដល់ នាងក្រេកអរសល់ ព្រឺព្រួចពុំពោះ
នាងនាថបែរបៀន មើលមៀនទៅស្មោះ យល់មហាបុរស
អង្គុយកាន់ឆត្រ ។

គន់អង្គទ្រង់ព្រាយ គន់រូបគន់កាយ ល្អល្អះពេកក្កាត់
មើលទៅសំលៀក ស្បៀកឯតំណាត់ រេបញ្ញកគាត់
ទទឹកជោកជាំ ។

នាងមើលសព្វប្រាណ ស្គាល់ជាក់ត្បិតបាន ចំណែកចំណាំ
កាលជួបពីតូច នាងដូចកត់ចាំ ជាហេតុបុព្វកម្ម
បានសាងនឹងគ្នា ។

ស្គាល់ជាក់ជាគូ ក្នុងប្រាណបានធូរ ស្រយាលទុក្ខា
ថែមទុក្ខទៀតថ្មី នឹងប្ដីកំព្រា ព្រាត់ប្រាសមាតា



ក្បៀណក្បៀយបាត់បង់ ។

៣៩៩– មកនៅឯគេ ឯកឥតទុតិយា គ្រមោចឯកអង្គ
វណ្ណាតែកន្ទុប កណ្ដាបផុយផង ថ្ពាំចំរះផ្ទិតផ្ទង់
ត្រដរស្បៀកទៅ ។

នាងមើលសព្វគ្រប់ ខនកក្រសញ្ញប់ សញ្ជឹងសុបសៅ
ស្រក់ទឹកនេត្រា ទុកក្ដួលក្ដៅ ហើយនាងស្រែកហៅ
នូវពាក្យមេត្រី ។

ឋានែអ្នកប្រុស កុំនៅឯនោះ មកនេះខ្ញាចអើ
មកពិសាស្លា ពិសាបារី បាពំងថ្មី ។
ទើបយកពីរហោ ។

ខ្ញុំនឹងឲ្យតាន សំពត់ហូលមាន អាវព្រៃបាក់ប៉ោ
ជាហ៊ុមបាក់ទៅ ចិនពាសសេខ្សា យ៉ាងក្រាស់យីហោ
ឲ្យស្រាយយ៉ាងឯក ។

ពង្សព្រុទ្ធង្គូរ ពួនាងហៅចូល ចេះតែប្រកែក
អ្នកលបមើលមៀន បែរបៀនចុងភ្នែក ស្គាល់ជាក់ពុំបែក
ដោយចិត្តញាណញេយ្យ ។

៤០០– ទឹកថានាងនេះ រូបរាងល្អម៉ោះ ដើតឆាយប្រពៃ
សមបុត្រពន្ធក ដែរគាតសេដ្ឋី មែនមិនខាន

ឯទៀតនានា ។

ទម្រើទូនប្រាណ នេះនៅគនគាន ដូចដើមតៅក៏
ទឹងបានមូលមិត្ត ស្គាលស្និទ្ធស្នេហា រួមសេរូបា
ជាគូពុំឃ្លាត ។

ឥឡូវសមទាន រូបរួមរូបហាន នៅនាក្នុងជាតិ
នេះទិកសង្វាយ ពីកាយនោមស្អាត ហេតុបាបបង្អាក
បង្ខិចឲ្យកាច់ ។

បង្អោនបង្អន់ ឲ្យប្រាសជំបន់ នូវធនធានទ្រព្យ
ព្រាត់ចាំងបិតា មាតាសីងស្លាប់ គិតទៅពុំគាប់
ពុំគួរបើបើ ។

ឲ្យគិតគួរស្តាយ រូបអង្គទន់ព្រាយ គមកលក្សណី
ទ្រទ្រសទ្រទន់ គន់គួរបេតី រីករួមមេត្រី
ជាគូស្នេហ៍ស្និទ្ធ ។

៤០៩– ស្ងួនអើយជាតិនេះ សមនឹងរបេះ ពុំបានដូចជិត
អសោចឥតការ ឥសារតំនិក តំនូវគូរគិត
គាប់ឥតប្រយោជន៍ ។

គឹកម្មនាំកាយ ឲ្យប្រាសព្រាត់ព្រាយ អសារអសោច
ក្លាលមួយម្នាក់ឯង កណ្តែងកណ្តោច ស្រងេះស្រងោច



ស្រែងលល់ទុក្ខ ។

វេលានេះហើយ ព្រលឹងបងអើយ បងបានឃើញមុខ
នៃនុជនួនល្អង ចិត្តបងរីកក្ក តឹងទ្រូងចើសចុក
ស្មើរព្លាយថ្មើមព្លាក់ ។

ទុសមប្អូនចាំ ប្អូនបានចំណាំ រូបរាងរៀមរក្ស
ទើបមានចិត្តថ្លៃ គាល័យនៃអ្នក មានចិត្តស្មោះស្ម័គ្រ
ជាគូនឹងគ្នា ។

ឃើញបងទុតិត ហៅឲ្យសំពត់ គាវព្រែជា ។
ជាហុមថ្មោងថ្មី បារីម្ហូស្វា ឥឡូវនេះណា
បងខ្វាចពេកក្រៃ ។

៤១០– នឹងទទួលយក របស់នោះមក ស្មៀកពាក់ប្រស្រ័យ
ខ្វាចក្រែងពុំស្វាត សាសព្នស្ងៃម ដល់តាស់ចាវ្រៃ
សេដ្ឋីបុស្សា ។

សមនឹងទីងទំ ប្រមាថកាយជំ ដល់កែវកខិង្គា
ជាប្អូនមាន៖ ចង់ឈ្នះចិន្តា ហើយប្រើភាសា
មកចាប់អញទៅ ។

បំបាត់ជន្មា ឝួសតោលអសារ ក្នុងព្រៃព្រាព្រៅ
គេខ្វាចអស់ឯង កណ្តែងឥតផៅ ឥតញាតិមួយនៅ

ជាទីពឹងគ្នា ។

គិតទៅសូវក្រ គួរកុំត្រេកអរ នឹងទ្រព្យធនធាន
ឈប់ចាំមើលព្រេង ខ្លាចក្រែងកមាន ល្ហើយទ្រាំអត់ឃ្លាន

តាមកម្មវេរ ។

អ្នកគិតសព្វគ្រប់ ក្រៀមក្រំសញ្ឈប់ កុំចេញចរចា
នាងនាថយំយល់ វិលខ្វល់ទុក្ខា អាណិតកស្តា

ស្មើក្ស័យជីវិត ។

៤១៩– នាងហៅទៀតស្មោះ ឱអ្នកកំលោះ អញ្ជើញមកជិត
អ្នកអើយអ្នកកុំ បារម្ភភ័យភិត អស់អែកក្នុងចិត្ត

ខ្វប់ខ្វាចឡើយ ។

ពន្លកពុទ្ធវង្ស ស្ដាប់នាងនោមយំ ហៅដូច្នោះហើយ
ទើបមានវាចា សាសន៍ស្វាស្ងើយ ថាឱនាងអើយ

អរពេកណាស់ណា ។

តែមោះខ្ញុំនេះ សំពត់ល្អផ្ទុះ លើសលើគ្នា
ខ្ញុំបាទមិនហ៊ាន គោងការនេះសា ស្លៀកទៅមិនជា

ប្រយោជន៍ប៉ុន្មាន ។

ខ្លួនខ្ញុំលំបាក លំបិនគោកយ៉ាក កំព្រាព្រាយប្រាណ
បែបនឹងតែងអង្គ ឲ្យអង្គសន្តាន ផ្ទឹមនឹងគេបាន



ទើបតែងស័ក្តិសម ។

អ្នកជាម្ចាស់ថ្នាក់ ហើយទើបបោះនេត្រ ឲ្យទៅអ្នកនាំ
ក្រោកក្រសោបបោសគូថ លោលោតលលាំ រួសគេខ្ញាំ

ខរខ្ទីនទៅផ្ទះ ។

៤២០– ឯនាងនិម្មល ក្រឡេកយំយល់ រៀមរត់ស្រឡះ
ពុំខ្វល់ទ្រព្យ នាងថប់ពេកណាស់ គឹងទ្រូងស្មើស្មុះ

គន់គិតថៃថា ។

ឱប្រុសព្រលឹង សមអ្នកខេទឹង នឹងប្អូនដឹងក៏
អ្នកស្ដាប់ប្អូនជាក់ ហើយអ្នកគិតថា ចិត្តប្អូនឫស្យា

ដូចជាឪពុក ។

បានជាអ្នកថ្លៃ អ្នករត់ដោះដៃ មិនមើលក្រោយមុខ
ឪពីនេះទៅ ប្អូននៅតែទុក្ខ កុំនឹកថាសុខ

សប្បាយឡើយណា ។

នាងនាថគិតហើយ ខ្វល់ទុក្ខពុំស្បើយ ស្រក់ទឹកនេត្រា
អាណោចអាណិត គន់គិតអនិច្ចា រឹងចុះវិសា

ដែលនាំនោះនៃ ។

យល់នាងយំយែក ក្រសោបស្រង់ទឹកភ្នែក ស្ទុះទៅវិលវៃ
ថាម្ដេចអ្នកនាង រូបកាន់ប្រពៃ ដែលនេះសាយភាល័យ

អាខ្សោះកលអ្វី ។

៤២៩– នាងផ្ញើយដោះសា　អ្នកអើយខ្ញុំអា-　ណិតអ្នកក្រក្រៃ
កំព្រោនកំព្រា　វេទនាឥតបី　ខ្ញុំគិតប្រណី
អ្នកនោះឯងណ៎ា ។

គាត់ក្រអ៊ីមេ៉ះ　សំពត់ដាចប្រេះ　ខំប្រឹងឧស្សាហ៍
ក្លាស់ខ្លាស់ដាច់ដិត　រ៉ឹកអាត្មា　ខ្ញុំគិតអនិច្ចា
ទឹងគាត់ពេកក្រៃ ។

ហេតុតែខ្សត់ខ្សោយ　ទៅខ្លាចមុខក្រោយ　ក្រែងកើតភាគ័យ
ពុំហ៊ានយកទាន　ខ្លាចមានទោសពៃរ៍　ខ្ញុំគិតខ្ញុំតែ
ខ្ញុំកើតទុក្ខ ។

រូបគាត់រូបឯង　កើតមកហើយតែង　ជាផ្លូវអនិច្ចំ
តែងតែលៃលង　ដូចកន់ថៃ　តាមដោយវេរ
វេរាបាបកាយ ។

បុរសនោះផ្ញើយ　ជាទុនាងអើយ　រូបយើងទាំងខ្សាយ
វេមង៉ជ្រៀងជ្រ　តែងតែកាយមាយ　ស៊ាប់សោយ
ពុំថេរឋិតឡើយ ។

៤៣០– ទើបបុរិសា　និយាយទៅថា　ម្តេចទៅនាងអើយ
អ្នកបានពីងខ្ញុំ　ឲ្យនាំជាក្រើយ　ឥឡូវបានហើយ



អ្នកគិតយ៉ាងណា ។

នាងផ្គាស់ផ្ញើយទៅ　ឲ្យខ្ញុំឥឡូវ　កុំអ្នកសង្កា
តែពុំបានគ្រប់　សាយសព្វប្រការ　ក្បិតខ្ញុំសញ្ញា
ទឹងចង់ឲ្យទាន ។

អ្នកនាំដល់ហើយ　ឥឡូវអ្នកអើយ　ត្រឡប់ជាខាន
ពុំដូចគំនិត　ដែលគិតចង់បាន　ជាអកុសលប្រាណ
ដូចអ្នកឃើញស្រាប់ ។

ខ្ញុំឲ្យអ្នកតែ　សំពត់មួយទេ　ពុំគ្រប់ប្រដាប់
ហើយនាងកើចយក　ឲ្យមកប្រញាប់　ហុចដល់កណ្តាប់
ដៃបុរិសា ។

បុរសស្រោកស្រួល　ព្រាកព្រមទទួល　យកទៅម្ចា
លានាងនិមល　ដើរដល់គ្រឹហា　នៃគ្រូអាចារ្យ
បរបូលទៅខ្មី ។

៤៣៩– ឯគ្រូអាចារ្យ　យល់ហើយសួរថា　ឯណាឃើញរឺ
ឯងប្រាប់អញថា　កូនមហាសេដ្ឋី　មានចិត្តប្រណី
អ្នកខ្សត់ទុគ៌ត ។

ឲ្យឯងនាំទៅ　បានដល់លំនៅ　ទីងឲ្យសំពត់
ឥឡូវម្តេចអា　ស្រទបះចកតេ　លៃមកចំហុត

មិនឃើញបានគី ។

បុរសនោះឆ្លើយ លោកគ្រូម្ចាស់អើយ ពិតដូចខ្ញុំស្តី
ខ្ញុំនាំទៅដល់ មណ្ឌលនាងស្រី នាងមានប្រណី
ហៅឲ្យចូលទៅ ។

នឹងឲ្យសំពត់ ស្រទបចេករត់ ចេញមកមិនទៅ
នាងយំនាងយែក នាងស្រែកហាហៅ ខ្ញុំចេញមកក្រៅ
ហៅក៏ពុំបាន ។

សំពត់នេះណា ពីនាងធីតា ទេវកល្យាណ
នាងឲ្យឈ្លួលខ្ញុំ នាំស្រទបចេកថ្កាន នេះនៅខ្លះទាន
ច្រើនណាស់នៅឡើយ ។

៤៤០– ក្បិតស្រទបចេក មិនមានគម្រែក កំភ្លឺកំហើយ
មិនខ្ទូលតាន នាងខានជាក្រើយ កុំអីលោកអើយ
បានគ្រប់ប្រដាប់ ។

ឯកាចារ្យឆ្លើយ ដូចោះគាអើយ ហៅមនុស្សឥតភ័ព្វ
គេគិតគាណិត ព្រោះឯងវ្យត់ទ្រព្យ គេរកគេកប់
តោះឲ្យតាន ។

ម្តេចឡើយមិនយក ហេតុតែអ្នកថោក មិនសមនឹងមាន
គេឲ្យទទេ វេះវេរប្រប្រាណ ពិតពុំចន់បាន



កំហើទៅចុះ ។

ពោធិសត្វ ឮពាក្យគាចារ្យ បន្ទោសដូច្នោះ
អ្នកអន្ទុយស្ងៀម ឥតមមៀមអេះអុះ គេសើចហសហុះ
ហាសហាយគ្រប់គ្នា ។

ឯនាងទេវី កាលក្រោយពោធិ ចេញចរឃ្លាតឃ្លា
នាងកែងខ្លល់ខ្លួន ពុំសុខអង្គា ក្តៅក្នុងអក
ពុំចេញសាសង ។

៤៤៥– នាងមានប្រាថ្នា ពុំឲ្យនរណា គេដឹងឡើយហោង
កែមនុស្សក្នុងផ្ទះ ស្រឡះជាម្តង ពុំឲ្យដឹងផង
មួយជាពីរឡើយ ។

នាងបានដឹងជាក់ ជារឿងសំណាក់ នៅគាចារ្យហើយ
នាងប្រាប់តាសី ថាហៃនាងអើយ ចិត្តអញពុំស្បើយ
នឹងអ្នកនោះណា ។

បង់កែឲ្យបាន អាណិតក្បិតគ្មាន សំពត់សោះសា
ប្រសិនឲ្យបាន សមមានផលា ជានិអស់អ្នកណា
ដទៃទៀតទៅ ។

នឹងបានបុណ្យនោះ ជៀងជួយអនុគ្រោះ អស់ទុក្ខសោកសៅ
នូវអស់ព្យាធិ ស្បើយពីក្តីក្តៅ ចូរចង់ទៅហៅ

យកមកឲ្យបាន ។

តាសីនោះណា បានស្តាប់កថា ទៅហ្វាយប្រែប្រាណ
ក្រោកក្រាកចាកចុះ ដើរលុះដល់ឋាន អាចារ្យពេជពាន
ពោធិសត្វនៅ ។

៦៤០– មេតាសីនោះ ចូលផិតចំពោះ ហើយប្រាយប្រាប់ទៅ
ថាហៃអ្នកប្រុស កំឡោះល្អញល្អៅ ពីនាងនោមនៅ
កេសរមាលា ។

ប្រើខ្ញុំឲ្យមក អញ្ជើញនាំយក អ្នកទៅផងគ្នា
នាងផ្តាំកំហិត ឲ្យគិតមេត្តា ឲ្យខំយាត្រា
ទៀតទៅកុំខាន ។

ស្រួចបចេកឆ្លើយ ថាហៃនាងអើយ ខ្ញុំទៅពុំបាន
គ្មិតមានវល់ អំពល់ក្នុងប្រាណ រៀបចូលដើនក្រាន
ដាំបាយឥឡូវ ។

តាសីថាយើ អ្នកប្រុសប្រសើរ កុំថាឆ្ងោះគួរ
វល់ម្តេចម្តា មេត្តាទៀតទៅ រំពេចប្រុសពៅ
សឹមវិលមកក្តាន ។

ពោធិឆ្លើយថា ល្ហើយនាងយាត្រា វិលវិញទៅឋាន
ជំរាបអ្នកនាង រូបពង់កល្យាណ កុំឲ្យគិតគាន



ឲ្យគាន់ខ្ញុំឡើយ ។

៦៤៥– តាសីនោះណា លួងលោមច្រើនគ្រា អួនអស់ចិត្តហើយ
ឲ្យប់ឲ្យកនាយកាយ កែក្រាយគោះគើយ ថែបង់ងើបងើយ
បៀនបៃថៃថា ។

ពុំគួរកម្មអើយ បាយបានឆ្អិនហើយ ហុងជ្រូកផងណា
ពោរពេញចាំងចាន មិនហ៊ានភោក្តា គោកតែចិត្តា
បេះត្រាំអត់បាន ។

ពន្លកផិនស្រី ពុំពាក្យតាសី ពុំចេញសង់ហ៊ាន
អ្នកក្រោកពុំលង់ ចូលក្នុងដើងក្រាន លាងឆ្នាំងលាងចាន
ដាំបាយព្រានើយ ។

មេនោះហួសចិត្ត ខញ់ខល់គំនិត លោមពុំបានឡើយ
ទើបវិលវិញថាន ដល់ឋាននាងហើយ ថាអ្នកម្ចាស់អើយ
អ្នកប្រុសនោះណា ។

ខ្ញុំលួងខ្ញុំល ខ្ញុំលោមឲ្យមក មិនព្រមសោះសា
បេះតែប្រតែក ជំនែករញ្ញាក គៀនណាស់ប្រែថា
ចូលដាំបាយបាក់ ។

៦៥០– នាងស្តាប់តាសី រឹងថៃមទុក្ខទី ផ្សារឆ្ងាចប្រមាត់
អស់អន្តការយ ដូចគេវៀលកាត់ ស្រន្ទុតស្រនាក់

ស្រងាកលើខ្នើយ ។

ដៃដាក់លើថ្ងាស់ គិតថាអ្នកមាស សំឡាញ់ម្ដូនអើយ
អ្នកកាត់អាល័យ គ្មានតែគិតឡើយ បានជាធ្វើហើយ
មិនមានអើពើ ។

ម្ដូនអ្នកសព្វថ្ងៃ វេទនាក្រៃក្រៃ ក្រាស់ក្រៃបើរើ
បើរះយ៉ាងណា កលការគិតធ្វើ ឲ្យដឹងដំណើរ
ទំនងអ្នកថ្លៃ ។

នាងតែងរំខាន់ នៅលង់ប្រមាណ ជាពីរបីថ្ងៃ
នាងហៅតាសី ស្រដីថាហៃ បងមកនេះនៃ
ធាប់ ១ ម៉ីម្នា ។

តាសីចូលថ្កាន ដល់នាងកល្យាណ ហើយទើបសួរថា
អ្នកហៅខ្ញុំប្រើ ឲ្យធ្វើអ្វីណា ឬមួយមានការ
ដូចម្ដេចអ្នកម្ចាស់ ។

៦៦៩– នាងថាបងអើយ អញគិតទៅហើយ ហៅមានកម្មក្រាស់
ចិត្តបងឲ្យតាន ក្រែងបានបុណ្យខ្វះ ឥឡូវស្រឡះ
គ្មានជាប់និស្ស័យ ។

អញចង់ប្រើបង ឲ្យទៅទៀតលង មើលការនេះនៃ
នាងថាម្លោះបាន កល្យាណប្រពៃ នាងចូលក្នុងវៃ



យកម្ជុលបៀកស្លា ។

ដាក់សឹងគ្រឿងទេស គ្រអូបពិសេស ពិសីពិសា
បារីបារាំង ខ្ទាំង ១ យ៉ាងជា បៀកស្រួចនាងនា-
រីរុំមកផង ។

ស្រីស្រស់ពិសេស យកហូលផ្កាទេស ពាក់ជាបៃញ៉ូង
អាវព្រយ៉ាងក្រាស់ ខ្សែមាសក្ងុំទង ក្រហមឆ្អិនឯង
មិនបាច់ឲ្យដឹង ។

ជាហ៊ុមបាក់ជាវ ក្លាំមភ្លៀងខ្មៅ ទឹមគ្រោះថ្មី ១
កន្ទ្រង់ក្រចាប់ សម្រាប់ហោថ្មី ហើយស្រួចស្រស់ស្រី
យកឆត្រស្បែកជើង ។

៦៧០– ហុចឲ្យតាសី មេនោះឃ្លាកទ្វី បរចេញចរចើង
ដល់ផ្ទះអាចារ្យ ម្ចាស់ម្ចាស់ស្រុះឡើង អន្ទិយបក់ជើង
សំពះពោធិ ។

ហើយហុចម្ដីម្ដា និយាយប្រាប់ថា ពីនាងទេវី
នាងឲ្យតានអ្នក ស្មៀកពាក់កុំពា- ភាល់កិតកំយី
បារម្ភខ្ញាចក្ស ។

នាងឲ្យតានស្មោះ កុំតែតិតដោះ ដោយកលសេចក្ដី
នាងឃើញអ្នកខ្សត់ ទុគ៌តក្រៃក្រ មានចិត្តប្រណី

អ្នកមិនមានស្បើយ ។

ពន្លកចំសពល មៀងមើលទៅយល់ សំពត់នោះហើយ
ឃើញគ្រប់ប្រការ ទឹកថានាងអើយ ចិត្តទៅនៅឡើយ

អាល័យរៀមរក្ស ។

ដូចរូបបង ពុំគួរទួនល្អង នាងទឹងនៅស្ត្រគ
គួរតែគោះតើយ ព្រងើយជាឥតជាក់ ស្ងួនអើយហេតុអ្នក

មាសមានមេត្តា ។

៤៧៩– ស្រីអើយបងថប់ ទឹងទទួលទ្រព្យ ពីប្អូនស្នេហា
ភ្ញាចក្រែងពុំស្ងាត់ ពុំបាត់វាចា ឮដល់ទៅមហា

សេដ្ឋីពុក ។

នៃប្អូនព្រលឹង ម៉្លោះហើយសមនឹង យកទៅធ្វើទុក្ខ
ខ្លួនបងឯកា អ្នកណាកប់មុខ ខ្លួនឃ្លាតពីស្រុក

ឥតពុកម្ដាយ ។

គិតហើយឆ្លើយថា ខ្ញុំអរហើយណា ទឹងនាងដោមធាយ
មានចិត្តមេត្តា ករុណាអន្តកាយ អាណោស់នាងកាយ

គេអ្វីផ្ញើគ្នា ។

តែជាខ្លួនខ្ញុំ ខ្សត់ខ្សោយពេកពុំ គួរគប្បីមាន
ទទួលទ្រព្យនេះ ល្អម៉្លេះលើសប្រមាណ ស្ងៀកម្ដេចនឹងបាន



បើខ្លួនសាត់ព្រាត់ ។

ចូរនាងយកទៅ ជូននាងស្រីពៅ ហើយផ្ដាំបងគាត់
ថាពីខ្លួនខ្ញុំ សូមសុំប្រណិប័តន៍ មកនាងស្រីក្ត

កុំឲ្យអន់អាក់ ។

៤៨០–ថាហើយក្រោកចេញ ចូលទៅក្នុងវិញ ពីងពួនលបលាក់
ឯមេតាសី ស្រងឹកក់តាក់ ស្រែកប្រាប់ថាអ្នក

ខ្ញុំលាទៅហើយ ។

លាស្រេចចេញចុះ ដើរដើរទៅផ្ទះ ផ្ទះនាងជាត្រើយ
ដល់ចូលសំពះ ថាម្ចាស់ខ្ញុំអើយ គាត់ពុំយកឡើយ

ណាអ្នកម្ចាស់ខ្ញុំ ។

តាសីនោះណា ផ្ដាំបធីតា សព្វគ្រប់អស់ដំ-
ណើរនៃមហាក្សត្រ បុរសរម្យ ពោធិ៍ទត្តម

ដោយជានចំនង ។

កេសរធីតា បានស្ដាប់ហើយណា នាងនាថស្រូវង
ទុក្ខទោមនស្ស ក្ដៅសៅហ្មង មិនចេញសួរសេង

ដល់គិតឡើយណា ។

អនិច្ចាកម្មអើយ កើតជាតិនេះហើយ ហៅសែនវេទនា
កើតទុក្ខក្នុងប្រាណ គ្មានបានស្រាលជា កម្មអ្វីកាលគ្រា

មុននេះតើម្តេច ។

៤៨៩– ប្រុសប្អូនអើយ អ្នកស្ងប់ប្អូនហើយ គ្មានទឹកដល់តិច
ប្អូនតែងទឹកអ្នក គ្មានកាក់គ្មានភ្ញប់ អ្នកបេះតែគេច
តើគិតយ៉ាងណា ។

ទុះធ្វើម្តេចបាន អ្នកមកក្នុងឋាន ប្អូនខឹងសួរការណ៍
ឲ្យដឹងពាក្យពេចន៍ ដូចម្តេចដូចម្តា ពោះកាចពោះជា
ខឹងរាយគិតទៀត ។

ឥឡូវនេះហើយ អ្នកប្រុសប្អូនអើយ ប្អូនរឹងបង្អៀត
ប្អូនគិតប្អូនគេច ប្អូនឈេចប្អូនភ្លៀត ប្អូនស៊ុបប្អូនសៀត
សព្វគ្រប់ប្រការ ។

អ្នកបែរអ្នកបៀត គ្មានបានឃើញស្នៀត ឃើញស្នាមគ្រងណា
មិនមានអាសូរ ឲ្យធូរចិត្តា កុំឲ្យប្អូនផ្សា
បន្តិចទៅអេះ ។

នេះម្តងបេះតែ ប្រកែកសាញសែ ចាំណោះចាំណោះ
ប្អូនរងទុក្ខគឹង វេរងរងស្ទើរប្រេះ ស្ទើរប្រាសរបេះ
របោចសាច់ស្នូត ។

៤៩០– បានឃើញមុខហើយ ស្មានជាខឹងស្បើយ ប្រែថែមទុក្ខគ្រួត
កន្ទេងកន្ទុ សព្វថ្ងៃស្ទើរផ្លួត រងទុក្ខវង្វែត



ថែមហើយថែមទៀត ។

ស្មាលាពាសា បើប្អូនប្រុសកំ ខឹងកាយផ្លាស់ភ្លៀត
សសៀរជ្រុលជ្រក សសឹកសសៀត សសុលជ្រែកជ្រៀត
សួរឲ្យអស់ការណ៍ ។

នេះប្អូនជាស្រី ទញ់ពាល់សេចក្តី ពន់ពេកណាស់ណា
ខឹងធ្វើដូចប្រុស ក្រែងខុសមាគ្រា ខឹងឈប់ក្រែងអា(១)
សារសោះទទេ ។

ទៅនាងគិត រិនក្នុងចិត្ត ទល់ទុក្ខកាត់ក្តៅ
កក្រោស្ងួតស្ងប់ សញ្ឈប់ស្មៀមនៅ តែងចាំមើលផ្លូវ
ចង់ជួបស្វាមី ។

សព្វថ្ងៃទៀនតែ លង់លុះដល់ខែ ចេត្រចូលឆ្នាំថ្មី
អស់មនុស្សស្រើបស្រុស ទាំងប្រុសទាំងស្រី ជ្រួលជ្រើមឃ្មាតខ្មី
យកការសយកប្រាក់ ។

៤៩៩– ទិញទៀនក្រមា ទិញខោសព្រក្កា មកជ្រលក់ល័ក្ត
ក្រហមរៀវរលឿង តាមតែចិត្តស្ម័គ្រ ខ្លះខ្មៅកក្វក់
ក្រមាស៊ុំដែរ ។

អ្នកខ្លះបេះផ្សំ ជ្រលក់ផតតំ បង្អើបង្អែ

១– ដែលត្រឹមត្រូវគឺ អ តែនេះសម្រួលតាមសម្ផស្សកាព្យ

បន្ដិតគេឯង　កោនកែនហាគេ　អ្នកខ្លះដើរតែ
ដើរតិកបន់ស្រី ។

ខ្លះស្លៀកសំពត់　ចាក់ផែសសសុទ្ធ　ពាក់អាវសៀមថ្មី
ដៃកាន់ចង្គឹះ　ល្អល្អះចុះដី　នាំគ្នាចាត់ស៊ី
សើចលេងសប្បាយ ។

ឯសស់ស្រីផង　តែងតួហ្មត់ហ្មង　ឥតមោះក្នុងកាយ
លាបលាយវីតអប់　ក្រអូបសព្វរាយ　ក្រឡប់ក្លិនក្លាយ
សស់អង្គឥន្ទ្រិយ ។

ស្រីខ្លះខ្លួនខ្មៅ　លាបម្រេងម្រោះមៀវ　ប្រឡាក់ល្អក់ល្អី
មើលទៅកញ្ចក់　សិតសក់វែកវី　ចាប់ក្រមាស៊ី
ផណ្ដប់គ្រលំ ។

៨០០— ខ្លះកាត់សក់ថ្មី　ស្អាតខ្លួនពិសី　ជោមដាក់កន្ធំ
ស្លៀកហូលចំប្រប់　ផណ្ដប់ដាហ៊ុម　ចុះដើរនិយម
និយាយលេងលង ។

ខ្លះចាស់ថ្ពាល់ផត　ដោះស្វិតចុះស្រុត　កែកាត់សក់ជ្រង
លាបម្រេងម្រោះមៀវ　ចាប់ខ្មៅផ្សំផង　ស្លៀកខៀវបៃតង
ក្រមាស៊ីនួន ។

ប្រុសស្រីអ្នកស្រុក　ស្រើបស្រួលគគុក　តាំងចិនតាំងយួន



ដើរលេងបៀប៉ោ　លេងផ្អកល់ខ្លួន　ខ្លះឈ្នះបានជួន
បែកគេបែកឯង ។

ពួកក្មេងតូចៗ　លេងល្បួងហក់ហ្វូង　ប្រឡូកប្រឡែង
លេងគោះពញាក់　លេងលាក់កន្សែង　លោតចាប់កូនខ្លែង
លេងលោតអន្ទាក់ ។

ឯអគ្គអាចារ្យ　មានចិត្តមេត្តា　ពន្យពោធិចក្រ
ប្រាប់ទៅកិរិយា　ថាឯងយកប្រាក់　ស៊ីដបានមួយកាក់
ឲ្យស្រទបបេក ។

៨០៥— ឯនាងកិរិយា　ស្ដាប់ហើយម្មា　ចូលក្នុងដំណេក
ចាក់សោយកថង់　ពីក្នុងត្រៃដេក　ភ្លក់តែងក្រឡេក
មៀងមើលនាយអាយ ។

ហើយលូកយកប្រាក់　ស៊ីងតូចមួយកាក់　កាន់ទុកនូវដៃ
ហើយរៀបផ្ចិតផ្ចង់　ចងថង់ដែលស្រាយ　ទុកដាក់សព្វសាយ
ចាក់សោត្រៃគ្រប់ ។

ស្រេចហើយម្មា　ចរចេញលីលា　ពីក្នុងបន្ទប់
ដើរដល់អាចារ្យ　ហើយណានាងឈប់　អង្គុយស្ងៀមស្ងប់
ហើយហុចប្រាក់នោះ ។

ទៅឲ្យកុមារ　ប្រាយប្រាប់ថាកា　យកប្រាក់ទៅចុះ

ឥឡូវចូលផ្នាំ　ចំណាំស្រីប្រុស　គេលេងសព្វសុស
តែកល់គ្នា ។
ចាំថ្ងៃគេលេង　ដូចខ្លះអាឯង　ទៅតាមចិត្ត
តោះឆ្ងាយតោះជិត　កុំគិតឡើយណា　លេងឲ្យសុខសា.(១)
ល្ហាយចិត្តនៃចៅ ។

៨១០– ពន្យរពោធិ៍ពុទ្ធា　ព្រះហើយម្ហ៊ីមា　ចរចូលជិតទៅ
ដល់ហើយក្រួញក្រាប　ស្រពាបស្មៀមនៅ　ខនស្ដាប់ប្រាប់
គរុយាអាចារ្យ ។
ទើបធ្លាស់ធ្ងើយថ្កាន　ចាំលោកឲ្យទាន　ខ្ញុំបាទនេះណា
ខ្ញុំតុំទៅលេង　ដោយល្បែងឡើយណា　ខុកចិញ្ចាហារ
ចំណីទាំងឡាយ ។
នឹងយកទៅព្រៃ　ទៅព្រឹកនេះនៃ　សែនដូនខ្មោចម្ដាយ
អាចារ្យបានស្ដាប់　សាសព្ទនិយាយ　ធ្ងើយថាទៅកាយ
ទៅគិតគាប់ហើយ ។
ទើបបោះប្រាក់នោះ　ឲ្យទៅចំពោះ　ពិតពុំលន់ឡើយ
ពោធិសត្វបរ　ត្រេកអរផែតស្បើយ　ស្រស់ក្រៃណាក្រើយ
រើសយកម្ហ៊ីមា ។

១– សម្រួលតាមសង្ខ្យាកាព្យ ។



បានដាក់ក្នុងថ្ពក់　វេចខ្ចប់សៀតផក់　ប្រយ័ត្នមហិមា
ដើរថយចេញមក　ស្រែកធ្វើការ　ចំរើអាចារ្យ
ដូចផែលប្រក្រតី ។

៨១១– លន់លុះសុរិយេ　សៀលជ្រៀងជ្រេ　ទៅបស្ចិមទិ៍
ព្រលឹមព្រលប់　លុះយប់រាត្រី　ពទ្ធកជនស្រី
ចរចូលនិទ្រា ។
ទឹកអរប៉ផ្អុក　ទឹកដេកពុំលក់　លន់លុះសុរិយា
កុនរឿងស្រឡះ　រះពីបូព៌ា　ក្រោកឡើងម្ហ៊ីមា
ដណ្ដាំបាយទឹក ។
ឆ្អិនស្រេចហើយណា　ដោះដូនអាចារ្យ　ឲ្យហូបពីព្រឹក
រួចស្រេចហើយមក　ស្រែកសុំផឹក　ប្រញាប់ក្បៀតទឹក
តែទៅមាគា ។
រួចស្រេចបរិបូណ៌　ក្បិណនោះមិនយូរ　ក្រាបលាអាចារ្យ
ចុះដល់ដីគិត　គន់គិតថែថា　អញដើរទៅណា
កុំឲ្យជួបនាង ។
រកចាស់ពោកកូរ　គិតរ៉េះរកផ្លូវ　នឹងជៀសវៀរវាង
គិតទៅសព្វគ្រប់　ពុញថប់វៀរវាង　ខញ់គុះគេងគាង
ខញ់ពាល់សេចក្ដី ។